# វិធានការអនាម័យនិងភូតគាមអនាម័យ ក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤

# មាតិកា

**ផ្នែកទី១** ទិដ្ឋភាពទូទៅនៃវិធានការអនាម័យនិងភូតគាមអនាម័យ (SPS) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs)

**ផ្នែកទី២** វិធានការអនាម័យនិងភូតគាមអនាម័យក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម (Cam-UAE CEPA)

**ផ្នែកទី៣** នីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យ

# ផ្នែកទី១

# ទិដ្ឋភាពទូទៅនៃវិធានការអនាម័យនិងភូតគាមអនាម័យ

# ( SPS ) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ( FTAs )

# អ្វីទៅជាវិធានការអនាម័យនិងភូតគាមអនាម័យ?

វិធានការអនាម័យនិងភូតគាមអនាម័យ សំដៅដល់បណ្តាវិធានការនានារបស់រដ្ឋាភិបាលនីមួយៗដែលបានដាក់ចេញក្នុងគោលបំណងការពារសុខភាពនិងអាយុជីវិតមនុស្ស សត្វ និងរុក្ខជាតិ ដូចតទៅ៖

| | | | |
|---|---|---|---|
| 1 | សុខភាពមនុស្ស ឬសត្វ | ទល់នឹង | ហានិភ័យបង្កឡើងដោយ សារធាតុបន្ថែម បន្សំសារធាតុបង្កគ្រោះថ្នាក់ បន្សំជាតពុល សពាង្គកាយបង្ករោគ ក្នុងអាហារ ភេសជ: និងចំណីសត្វ |
| | (Human or Animal Health) | From | ( risks arising from additives, contaminants, toxins or disease organisms in food, drink, feedstuff ) |
| 2 | ជីវិតមនុស្ស | ទល់នឹង | រុក្ខជាតិ ឬ សត្វដែលមានចំលងជំងឺ |
| | (Human Life) | From | (plant- or animal-carried diseases) |
| 3 | ជីវិតសត្វ ឬ រុក្ខជាតិ | ទល់នឹង | សមាសភាពចង្រៃ ជំងឺ សពាង្គកាយបង្ករោគ |
| | (Animal or plant life ) | From | pests, diseases, disease-causing |
| 4 | ប្រទេស | ទល់នឹង | ការខូចខាតដទៃទៀត ដែលបង្កឡើងដោយ ការឆ្លងរីករាលដាលចូលនៃសមាសភាពចង្រៃ |
| | (A Country) | From | ( other damage caused by entry, establishment or spread of pests) |

វិធានការ SPS មានវិសាលភាពលើការការពារសុខភាពរបស់មច្ឆជាតិ សត្វព្រៃ ព្រៃឈើ និងផ្កាព្រៃ (wild flora) ផងដែរ។

# អ្វីទៅជាវិធានការអនាម័យនិងភូតគាមអនាម័យ?

កិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO-SPS Agreement) - សុខដុមនីយកម្មវិធានការ SPS របស់សមាជិក

ស្តង់ដារ

គោលការណ៍ណែនាំ

អនុសាសន៍



# វិធានការ SPS និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

វិធានការអនាម័យនិងភូតគាមអនាម័យ គឺជាវិធានការមួយដែលមិនអាចខ្វះបានស្របតាមកិច្ចព្រមព្រៀងក្នុងបរិបទពាណិជ្ជកម្មសេរី៖

- ដើម្បីសម្របសម្រួលការនាំចេញរុក្ខជាតិ ផលិតផលរុក្ខជាតិ និងកម្មវត្ថុជាប់កម្រិតកំណត់ដទៃទៀត
- ដើម្បីទប់ស្កាត់ការនាំចូលរុក្ខជាតិ ផលិតផលរុក្ខជាតិ និងកម្មវត្ថុជាប់កម្រិតកំណត់ដទៃទៀតដែលមានសក្តានុពលហានិភ័យចម្លងសមាសភាពចង្រៃមកបំផ្លាញរុក្ខជាតិ ផលិតផលកម្មកសិកម្មកម្ពុជា (សិទ្ធិការពារខ្លួនដើម្បីការពារសុខភាព ឬជីវិតមនុស្ស សត្វ និងរុក្ខជាតិនៅក្នុងដែនដីរបស់ខ្លួន)
- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អនុញ្ញាតឱ្យមានការធ្វើសេរីភាវូបនីយកម្មទីផ្សារផលិតផលកសិកម្មដោយជាប់របាំងពន្ធគយក្នុងកម្រិតទាបជាងមុន ឬ ពុំជាប់របាំងពន្ធគយទាំងស្រុងបានជាច្រើនបន្ទាត់ពន្ធ ប៉ុន្តែពុំមានន័យថា ប្រទេសជាដៃគូក្នុងកិច្ចព្រមព្រៀងអាចនាំចេញនាំចូលទំនិញជាផលិតផលកសិកម្ម ដោយមិនជាប់របាំងមិនមែនពន្ធគយ ដែលរួមមានផងដែរនូវរបាំងSPS ។

# វិធានការ SPS និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (ត)

- ការនាំចេញទំនិញជាផលិតផលកសិកម្មពីកម្ពុជា ត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវ SPS និងសុវត្ថិភាពម្ហូបអាហារ (Food safety) ដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាធរមានរបស់ប្រទេសនាំចូលជាដៃគូនៅក្នុង FTAs។
- ដូចគ្នាដែរ ការនាំទំនិញកសិកម្ម ឬម្ហូបអាហារចូលប្រទេសកម្ពុជា ក៏ជាកម្មវត្ថុស្ថិតក្រោមរបបគ្រប់គ្រងស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹង SPS របស់កម្ពុជាផងដែរ។

# ស្ថានភាពនៃការពង្រឹងសមត្ថភាព SPS

ក្នុងគោលដៅឆ្ពោះទៅជម្នះឱ្យបាននូវរបាំង SPS ឱ្យកាន់តែមានប្រសិទ្ធភាព សូមជម្រាបជូនអំពីស្ថានភាពនៃលទ្ធផលសំខាន់ៗនៃដំណើរការពង្រឹងសមត្ថភាព SPS ទាំងលើផ្នែកទន់និងផ្នែករឹង ដូចខាងក្រោម៖

❖ **ផ្នែកទន់៖**

- សមិទ្ធផលផ្នែកទន់ដ៏សំខាន់មួយដែលសម្រេចបាននោះគឺការអនុម័តឱ្យប្រើប្រាស់នូវច្បាប់ស្ដីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យ។ ច្បាប់នេះ ផ្ដល់ជាក្របខណ្ឌគតិយុត្តសម្រាប់ការអភិវឌ្ឍប្រព័ន្ធ SPS សម្រាប់អនុវិស័យដំណាំទាំងមូល។
- សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្នែកការពាររុក្ខជាតិនិងភូតគាមអនាម័យ។ ឯកសារនេះ នឹងផ្ដល់ជាផែនទីចង្អុលបង្ហាញផ្លូវសម្រាប់ពន្លឿនដំណើរការកសាងសមត្ថភាពផ្នែក SPS ទាក់ទងនឹងរុក្ខជាតិ និងផលិតផលរុក្ខជាតិ។

# ស្ថានភាពនៃការពង្រឹងសមត្ថភាព SPS ( ត )

❖ **ផ្នែករឹង៖**

តាមរយៈកម្មវិធី ASPIRE-AT ដែលគាំទ្រដោយហិរញ្ញប្បទានពី EIB និង EU ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងសាងសង់ហេដ្ឋារចនាសម្ព័ន្ធជួយគាំទ្រដល់ការងារ SPS ចំនួន ១១ ទីតាំងរួមមាន៖ មន្ទីរពិសោធន៍ជាតិកសិកម្ម ចំនួន០១, មន្ទីរពិសោធន៍សុខភាពរុក្ខជាតិចំនួន ០១, ការិយាល័យត្រួតពិនិត្យភូតគាមអនាម័យថ្នាក់តំបន់ចំនួន០៥, មណ្ឌលស្រាវជ្រាវការធ្វើប្រព្រឹត្តកម្មភូតគាមអនាម័យចំនួន០១ និងស្ថានីយ៍ពិសោធន៍ សុខភាពរុក្ខជាតិចំនួន០៣។



# ផ្នែកទី២ វិធានការអនាម័យនិងភូតគាមអនាម័យ ក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម ( Cam-UAE CEPA )

# ព័ត៌មានទូទៅនៃវិធានការ SPS ក្រោម Cam-UAE CEPA

នៅក្នុងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម (Cam-UAE CEPA) វិធានការអនាម័យនិងភូតគាមអនាម័យ (SPS Measures) គឺស្ថិតនៅក្នុងជំពូកទី៥ និងមាន ១២មាត្រា រួមមានជាអាទិ៍៖

| | |
|---|---|
| មាត្រា៥.១ និយមន័យ | មាត្រា៥.៧ សមមូលភាព |
| មាត្រា៥.២ គោលដៅ | មាត្រា៥.៨ ការប្រែប្រួលទៅតាមលក្ខខណ្ឌតំបន់រួមបញ្ចូលទាំងតំបន់គ្មានសមាសភាពចង្រៃឬជំងឺ និងតំបន់ដែលមានសមាសភាពចង្រៃឬជំងឺកម្រិតទាប |
| មាត្រា៥.៣ វិសាលភាព | ៥.៩ ការវាយតម្លៃហានិភ័យ |
| មាត្រា៥.៤ បទប្បញ្ញត្តិទូទៅ | ៥.១០ វិធានការបន្ទាន់ |
| មាត្រា៥.៥ អាជ្ញាធរមានសមត្ថកិច្ចនិងចំណុចទំនាក់ទំនង | ៥.១១ តម្លាភាព |
| មាត្រា៥.៦ អនុគណៈកម្មាធិការវិធានការ SPS | ៥.១២ កិច្ចសហប្រតិបត្តិការនិងការកសាងសមត្ថភាព |

# មាត្រា៥.១ និយមន័យ

មាត្រា ៥.១ បានឆ្លុះបញ្ចាំងនូវភាពច្បាស់លាស់ និងភាពស៊ីសង្វាក់គ្នាអំពីរបៀបដែលវិធានការអនាម័យនិងភូតគាមអនាម័យត្រូវបានកំណត់ និងអនុវត្តរវាងភាគីទាំងពីរនៅក្នុងកិច្ចព្រមព្រៀងពិសេសការប្រើប្រាស់វាក្យស័ព្ទដែលទទួលស្គាល់ជាអន្តរជាតិ (វាក្យស័ព្ទដែលកំណត់ក្នុងឧបសម្ព័ន្ធ A នៃ WTO-SPS Agreement) និងការកំណត់នូវវាក្យស័ព្ទគន្លឹះបន្ថែមចំនួន២គឺអាជ្ញាធរមានសមត្ថកិច្ច និងវិធានការបន្ទាន់។

បញ្ញត្តិនេះ ធានាថាភាគីទាំងពីរគឺមានការយល់ដឹងដូចគ្នាទាក់ទងនឹងបទប្បញ្ញត្តិដែលមានភាពចាំបាច់សម្រាប់ការគ្រប់គ្រងហានិភ័យទាក់ទងនឹងសុខភាព (មនុស្ស សត្វ និងរុក្ខជាតិ) និងការរក្សាការធ្វើពាណិជ្ជកម្មប្រកបដោយតម្លាភាព។

# មាត្រា៥.២ គោលដៅ

មាត្រា៥.២ បានឆ្លុះបញ្ចាំងអំពីគោលដៅរបស់ជំពូកវិធានការអនាម័យនិងភូតគាមអនាម័យក្រោមកិច្ចព្រមព្រៀងនេះ ដោយបានបង្ហាញអំពីការណែនាំយ៉ាងប្រត្យក្សអំពីគោលបំណងនិងគោលដៅសម្រាប់ការអនុវត្តវិធានការអនាម័យនិងភូតគាមអនាម័យ៖

១. ការការពារសុខភាពនិងការសម្រួលពាណិជ្ជកម្ម
២. ការពង្រឹងកិច្ចសហប្រតិបត្តិការលើការអនុវត្តកិច្ចព្រមព្រៀង SPS
៣. ការពង្រឹងទំនាក់ទំនង ការពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរមានសមត្ថកិច្ចទាំងពីរ
៤. ការចៀសវាងនូវរបាំងពាណិជ្ជកម្មដែលមិនសមហេតុផល
៥. ការលើកកម្ពស់តម្លាភាព
៦. ការចូលរួមនៅក្នុងស្តង់ដារអន្តរជាតិ។

# មាត្រា៥.៣ វិសាលភាព

មាត្រា៥.៣ បង្ហាញនូវវិសាលភាពនៃវិធានការអនាម័យនិងភូតគាមអនាម័យរបស់ភាគីដែលអាចជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោល លើពាណិជ្ជកម្មរវាងភាគីទាំងពីរ។

នៅក្នុងលក្ខខណ្ឌជាក់ស្តែង រាល់វិធានការ SPS នឹងអនុវត្តឡើងតែក្នុងគោលបំណងចាំបាច់សម្រាប់ការការពារសុខភាពមនុស្ស (សុវត្ថិភាពម្ហូបអាហារ) សុខភាពសត្វ និងសុខភាពរុក្ខជាតិ។ ឧទាហរណ៍នៃវិធានការ SPS៖ ការហាមឃាត់ការនាំចូល លក្ខខណ្ឌតម្រូវព័ត៌មាន ប្រព្រឹត្តិកម្មភូតគាមអនាម័យ Pesticide tolerances, Food additive approval procedures ការធ្វើតេស្ត ការវាយតម្លៃហានិភ័យជាដើម។ល។

# មាត្រា៥.៤ បទប្បញ្ញត្តិទូទៅ

មាត្រា៥.៤ បានគូសបញ្ជាក់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនៅក្រោមកិច្ចព្រមព្រៀង SPS នៃអង្គការ WTO ហើយបទប្បញ្ញត្តិនេះក៏ចូលរួមធានាថាកិច្ចព្រមព្រៀង SPS នៅតែជាក្របខ័ណ្ឌចម្បងសម្រាប់ការដោះស្រាយបញ្ហាទាក់ទងនឹងការអនុវត្តវិធានការ SPS ចំពោះពាណិជ្ជកម្ម។

# មាត្រា៥.៥ អាជ្ញាធរមានសមត្ថកិច្ចនិងចំណុចទំនាក់ទំនង

មាត្រា៥.៥ បានផ្តល់នូវច្រកទំនាក់ទំនងរវាងអាជ្ញាធរមានសមត្ថកិច្ចនិងចំណុចទំនាក់ទំនងដែលទទួលខុសត្រូវលើការងារអនាម័យនិងភូតគាមអនាម័យរបស់ភាគីទាំងពីរ ជាមួយនឹងពេលវេលាកំណត់ច្បាស់លាស់សម្រាប់កិច្ចពិភាក្សា និងការជូនដំណឹងទាក់ទងនឹងបញ្ហា និងការប្រែប្រួលនៃវិធានការ SPS របស់ភាគី។

# មាត្រា៥.៦ អនុគណៈកម្មាធិការវិធានការ SPS

មាត្រា៥.៦ បានអនុញ្ញាតឱ្យបង្កើតនូវអនុគណៈកម្មាធិការវិធានការ SPS ដែលមានសមាសភាពពីតំណាងរដ្ឋាភិបាលនៃភាគីសមាជិកនីមួយៗដែលទទួលខុសត្រូវលើការងារអនាម័យនិងភូតគាមអនាម័យ។ អនុគណៈកម្មាធិការនេះ គឺជាវេទិកាសម្រាប់៖

១. ធ្វើឱ្យប្រសើរឡើងនូវការយោគយល់គ្នាទៅវិញទៅមកអំពីវិធានការ SPS និង បទប្បញ្ញត្តិ និងដំណើរការប្រតិបត្តិការរបស់ភាគីនីមួយៗដែលទាក់ទងនឹងវិធានការទាំងនោះ។

២. ផ្លាស់ប្តូរព័ត៌មានអំពីការអនុវត្តជំពូកវិធានការ SPS នេះ។

បន្ថែមពីនេះ ប្រសិនបើភាគីសមាជិកពិនិត្យឃើញថា មានការរំខានដល់ពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងការអនុវត្តវិធានការអនាម័យនិងភូតគាមអនាម័យ ភាគីនោះអាចស្នើសុំការពិគ្រោះយោបល់បច្ចេកទេសតាមរយៈអនុគណៈកម្មាធិការវិធានការ SPS ក្នុងគោលបំណងសម្រួលពាណិជ្ជកម្ម។

# មាត្រា៥.៧ សមមូលភាព

មាត្រា៥.៧ បង្ហាញពីការទទួលស្គាល់នូវគោលការណ៍សមមូលភាពនៃវិធានការ SPS របស់ភាគីក្រោមកិច្ចព្រមព្រៀង SPS នៃអង្គការ WTO។ ភាគីទាំងពីរ ក៏ឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការកំណត់សមមូលភាព និងគោរពតាមនីតិវិធីសម្រាប់ការកំណត់សមមូលភាពនៃវិធានការ SPS ស្របតាមសេចក្តីសម្រេចរបស់ WTO SPS Committee ព្រមទាំងស្តង់ដារ គោលការណ៍ណែនាំ និងអនុសាសន៍អន្តរជាតិ។ ទោះបីជាយ៉ាងនេះក្តី ភាគីទាំងពីរ ក៏ត្រូវអនុវត្តតាមតម្រូវការចាំបាច់ផ្សេងទៀតរបស់ប្រទេសនាំចូលផងដែរ។

# មាត្រា៥.៨ ការប្រែប្រួលទៅតាមលក្ខខណ្ឌតំបន់ រួមបញ្ចូលទាំងតំបន់គ្មានសមាសភាពចង្រៃឬជំងឺ និងតំបន់ដែលមានសមាសភាពចង្រៃឬជំងឺក្នុងកម្រិតទាប

មាត្រា៥.៨ បង្ហាញពីការទទួលស្គាល់នូវគោលការណ៍ប្រែប្រួលទៅតាមលក្ខខណ្ឌតំបន់ រួមបញ្ចូលទាំងតំបន់គ្មានសមាសភាពចង្រៃឬជំងឺ និងតំបន់ដែលមានសមាសភាពចង្រៃឬជំងឺក្នុងកម្រិតទាប ដែលចូលរួមផ្តល់នូវផលប្រយោជន៍រួមដល់ភាគីទាំងពីរ ស្របតាមកិច្ចព្រមព្រៀង SPS នៃអង្គការ WTO។ ភាគីទាំងពីរ ក៏ឯកភាពពង្រឹងកិច្ចសហប្រតិបត្តិលើការទទួលស្គាល់នូវលក្ខខណ្ឌតំបន់ និងគោរពតាមនីតិវិធី ដោយអនុលោមតាមសេចក្តីសម្រេចរបស់ WTO SPS Committee ព្រមទាំងស្តង់ដារ គោលការណ៍ណែនាំ និងអនុសាសន៍អន្តរជាតិ។

ជារួម មាត្រានេះឆ្លុះបញ្ចាំងកិច្ចសហប្រតិបត្តិការទៅវិញទៅមកដើម្បីគ្រប់គ្រង និងទទួលស្គាល់តំបន់ដែលមានហានិភ័យនៃសមាសភាពចង្រៃ ឬជំងឺផ្សេងៗគ្នា ដោយគោរពស្តង់ដារអន្តរជាតិ។

# មាត្រា៥.៩ ការវាយតម្លៃហានិភ័យ

មាត្រា៥.៩ ផ្តល់នូវការធានាថា វិធានការ SPS ត្រូវបានបកស្រាយតាមយុត្តិកម្មបច្ចេកទេស និងតាមបែបវិទ្យាសាស្ត្រ តាមរយៈការវាយតម្លៃហានិភ័យប្រកបដោយភាពត្រឹមត្រូវ និងតម្លាភាព ហើយជម្រើសវិធានការសម្រាប់ការគ្រប់គ្រងហានិភ័យ គឺមិនរឹតត្បិតពាណិជ្ជកម្មលើសពីតម្រូវការចាំបាច់ក្នុងការការពារអាយុជីវិត និងសុខភាពមនុស្ស សត្វ ឬរុក្ខជាតិ។ មាត្រានេះ ក៏បានផ្តល់នូវការធានាអំពីតម្លាភាពនិងកិច្ចសន្ទនានៅក្នុងអំឡុងពេលដំណើរការវាយតម្លៃហានិភ័យ (បច្ចុប្បន្នភាពព័ត៌មាននៃដំណើរការវិភាគហានិភ័យសមាសភាពចង្រៃរបស់ប្រទេសនាំចូល)។ បន្ថែមពីនេះ មាត្រានេះក៏ធានាថា ប្រទេសនាំចូលនឹងមិនរារាំងការនាំចូល នៅពេលដែលខ្លួនបាននិងកំពុងធ្វើការត្រួតពិនិត្យឡើងនូវវិធានការអនាម័យនិងភូតគាមអនាម័យពាក់ព័ន្ធនឹងទំនិញដែលបាននិងកំពុងនាំចូលនោះ។

# មាត្រា៥.១០ វិធានការបន្ទាន់

មាត្រា៥.១០ ឆ្លុះបញ្ចាំងថារាល់ការដាក់វិធានការបន្ទាន់ណាមួយ ភាគីត្រូវជូនដំណឹងភ្លាមៗ នៅលើប្រព័ន្ធជូនដំណឹង WTO SPS notification system ត្រូវត្រួតពិនិត្យឡើងវិញនូវវិធានការនោះតាមកាលបរិច្ឆេទកំណត់ និងត្រូវចែករំលែកលទ្ធផលនៃការត្រួតពិនិត្យឡើងវិញនោះទៅកាន់ភាគីម្ខាងទៀតនៅពេលមានការស្នើសុំ។

# មាត្រា៥.១១ តម្លាភាព

មាត្រា៥.១១ ធានាថាភាគីទាំងពីរមានតម្លាភាពអំពីវិធានការ SPS របស់ខ្លួន ជូនដំណឹងគ្នាទៅវិញទៅមកអំពីការផ្លាស់ប្តូរវិធានការ SPS ដែលអាចជះឥទ្ធិពលដល់ពាណិជ្ជកម្ម និងការចែករំលែកនូវព័ត៌មានជាភាសាច្បាស់លាស់ និងអាចប្រើប្រាស់បាន (ភាសាអង់គ្លេសប្រសិនបើមាន)។

# មាត្រា៥.១២ កិច្ចសហប្រតិបត្តិការនិងការកសាងសមត្ថភាព

មាត្រា៥.១២ សង្កត់ធ្ងន់លើកិច្ចសហប្រតិបត្តិការ និងការគាំទ្រទៅវិញទៅមក ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តវិធានការ SPS និងលុបបំបាត់ឧបសគ្គដែលពុំចាំបាច់ចំពោះពាណិជ្ជកម្ម។

# ផ្នែកទី៣

# នីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រត្រួតពិនិត្យគាមអនាម័យ

# នីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យ

## ❑ បទដ្ឋានគតិយុត្តជាតិ

ការផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យសម្រាប់នាំចេញ នាំចេញទៅវិញ និង វិញ្ញាបនបត្រភូតគាមអនាម័យនាំចូល ត្រូវបានអនុវត្តតាម៖

- ច្បាប់ស្តីពីការការពាររុក្ខជាតិនិងភូតគាមអនាម័យនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជ (២០០៨)
- អនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ
- ប្រកាសលេខ៣៤៦ ប្រក.កសក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០ ស្តីពីនីតិវិធីនៃការត្រួតពិនិត្យភូតគាមអនាម័យ






# នីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យ (ត)

## ❑ បទដ្ឋានគតិយុត្តអន្តរជាតិ

- កម្ពុជា ជាភាគីហត្ថលេខីនៃអនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ (IPPC/UN-International Plant Protection Convention) តាំងពីឆ្នាំ១៩៥២
- តួនាទីភាគីហត្ថលេខីក្នុងវិញ្ញាបនកម្មភូតគាមអនាម័យ៖ មាត្រា ៥.២a នៃអនុសញ្ញា IPPC កំណត់ថា ការត្រួតពិនិត្យ និងសកម្មភាពដទៃដែលជំរុញគាំទ្រដល់ការផ្តល់វិញ្ញាបនបត្រភូតគាមគាមអនាម័យ (Phytosanitary Certificate) ត្រូវតែអនុវត្តដោយ ឬ ស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃអង្គភាពជាតិការពាររុក្ខជាតិ (Shall be carried out only or under authority on the Official Plant Protection Organization)
- កិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យនៃអង្គការ WTO។



# នីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យ (ត)

## ❑ ដំណាក់កាលទី១ ការដាក់ពាក្យស្នើសុំ

ក្នុងរយៈពេលមិនលើសពី១០(ដប់)ថ្ងៃនៅមុនពេលធ្វើការនាំចេញពីព្រះរាជាណាចក្រកម្ពុជានូវរុក្ខជាតិ ផលិតផលរុក្ខជាតិ និងទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យផ្សេងទៀត ដោយអនុលោមតាមលក្ខខណ្ឌភូតគាមអនាម័យរបស់ប្រទេសនាំចូល អ្នកនាំចេញត្រូវដាក់ពាក្យស្នើសុំត្រួតពិនិត្យភូតគាមអនាម័យនៅឯអគ្គនាយកដ្ឋានកសិកម្ម (ច្រកចេញចូលតែមួយ) ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោមៈ

- ពាក្យស្នើសុំត្រួតពិនិត្យភូតគាមអនាម័យ
- វិក្កយបត្រនិងបញ្ជីវេចខ្ចប់ទំនិញ
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ
- វិញ្ញាបនបត្របញ្ជាក់ការធ្វើប្រព្រឹត្តិកម្ម
- ឯកសារតម្រូវពាក់ព័ន្ធផ្សេងទៀត។

# នីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យ (ត)

- **ដំណាក់កាលទី២ ការត្រួតពិនិត្យមើលឯកសារស្នើសុំ**

មន្ត្រីត្រួតពិនិត្យឯកសារ នឹងពិនិត្យមើលឯកសារពាក្យស្នើសុំនិងឯកសារភ្ជាប់ពាក្យស្នើសុំ ដើម្បីប្រាកដថាឯកសារមានភាពត្រឹមត្រូវ ពេញលេញ និងស្របតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យរបស់ប្រទេសនាំចូល។

- **ដំណាក់កាលទី៣ ការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញ**

មន្ត្រីត្រួតពិនិត្យភូតគាមអនាម័យដែលទទួលបានការចាត់តាំង នឹងចុះត្រួតពិនិត្យទំនិញផ្ទាល់នៅទីតាំងឡើងទំនិញឬឃ្លាំងផ្ទុកទំនិញនាំចេញ និងមធ្យោបាយផ្ទុកទំនិញផងដែរ ដើម្បីធានាថាទំនិញនាំចេញមានអនុលោមភាពជាមួយនឹងលក្ខខណ្ឌតម្រូវនាំចូល និងធានាបាននូវសន្តិសុខភូតគាមអនាម័យនៅពេលនាំចេញ។

# នីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យ (ត)

## ❑ ដំណាក់កាលទី៤ ការចេញផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យ

បន្ទាប់ពីបានត្រួតពិនិត្យភូតគាមអនាម័យជូនអ្នកនាំចេញរួច អង្គភាពជំនាញទទួលបន្ទុកការការពាររុក្ខជាតិនិងភូតគាមអនាម័យ នឹងចេញផ្តល់វិញ្ញាបនបត្រភូតគាមអនាម័យចំពោះតែទំនិញដែលមានអនុលោមភាព តាមរយៈលទ្ធផលនៃការត្រួតពិនិត្យភូតគាមអនាម័យរបស់មន្ត្រីត្រួតពិនិត្យភូតគាមអនាម័យ (ពុំមានហានិភ័យនៃសមាសភាពចង្រៃ ស្របតាមលក្ខខណ្ឌតម្រូវនាំចូល...)។



# នីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រភូតគាមអនាម័យ (ត)

## ❑ បែបបទនៃការត្រួតពិនិត្យភូតគាមអនាម័យសម្រាប់ការនាំចេញ

**ឯកសារតម្រូវសម្រាប់ការស្នើសុំ PC :**

- ពាក្យស្នើសុំត្រួតពិនិត្យភូតគាមអនាម័យ
- វិក្កយបត្រនិងបញ្ជីវេចខ្ចប់ទំនិញ
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ
- វិញ្ញាបនបត្របញ្ជាក់ការធ្វើប្រព្រឹត្តិកម្ម












# វឌ្ឍនភាពនៃការចរចាបើកទីផ្សារ

| ឈ្មោះផលិតផល | កាលបរិច្ឆេទ |
|---|---|
| ❖ **ការចរចាបើកទីផ្សារជាមួយប្រទេសចិន** | |
| ១. អង្ករនិងកញ្ចុងអង្ករ | ចំណាយរយៈពេលអស់**៦ឆ្នាំ** (២០០៤-២០១០) |
| ២. ដំឡូងមីក្រៀម | ចំណាយរយៈពេលអស់**៦ឆ្នាំ** (២០០៤-២០១០) |
| ៣. គ្រាប់ពោត | ចំណាយរយៈពេលអស់**៤ឆ្នាំ** (២០១១-២០១៤) |
| ៤. ផ្លែចេក | ចំណាយរយៈពេលអស់**៥ឆ្នាំ** (២០១៤-២០១៨) |
| ៥. ផ្លែស្វាយ | ចំណាយអស់រយៈពេល**៤ឆ្នាំ** (២០១៨-២០២១) |
| ៦. ផ្លែមៀនប៉ៃលិន | ចរចាឆ្នាំ២០១៩ បញ្ចប់ខែមីនា ២០២២ |
| ៧. ម្រេច | ចរចាឆ្នាំ២០២២បញ្ចប់ខែវិច្ឆិកា ២០២២ |
| ៨. ផ្លែដូង | ចរចាឆ្នាំ២០២៣ និងបានសម្រេចចុះហត្ថលេខាលើពិធីសារជាផ្លូវការកាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣។ |
| ចំពោះមុខផលិតផលកសិកម្មដែលមានសក្តានុពលនាំចេញ និងត្រូវបានបញ្ចូលទៅក្នុងផែនការ សកម្មភាពចរចាបើកទីផ្សារជាមួយប្រទេសចិនបន្ទាប់រួមមាន ទុរេន ខ្នុរ និងម្នាស់។ | |
| ❖ **ការបើកទីផ្សារជាមួយប្រទេសកូរ៉េ** | |
| ១. ផ្លែស្វាយ | ចំណាយរយៈពេលអស់**៧ឆ្នាំ** (២០០៩-២០១៥) តែនៅមិនអាចនាំចេញបានដោយហេតុថានៅមិនទាន់អាចបំពេញតាមលក្ខខណ្ឌតម្រូវភូតគាមអនាម័យនៃប្រទេសកូរ៉េ លុះដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ កម្ពុជាអាចបំពេញបាននូវលក្ខខណ្ឌតម្រូវភូតគាមអនាម័យ (លក្ខខណ្ឌនៃការធ្វើប្រព្រឹត្តិកម្ម VHT) ។ |
| ❖ **ការចរចាបើកទីផ្សារជាមួយប្រទេសថៃ** | |
| ១. ផ្លែស្វាយ | ចំណាយរយៈពេល**១ឆ្នាំ** (២០១៥-២០១៦) |
| ២. ផ្លែមៀន | ចាប់ផ្តើមចរចាតាំងពីឆ្នាំ ២០១៩ រហូតដល់បច្ចុប្បន្នភាគីថៃបានធ្វើការឆ្លើយតបថាឈានដល់ដំណាក់កាលនៃការវិភាគហានិភ័យសមាសភាពចង្រៃ។ |

❖ **ការចរចាបើកទីផ្សារជាមួយប្រទេសវៀតណាម**

| | |
|---|---|
| ១. ផ្លែស្វាយ ចេក ស្រកានាគ | ចំណាយរយៈពេល**១ឆ្នាំ** (ដើមឆ្នាំ២០១៧-ចុងឆ្នាំ២០១៧) |
| ២. ផ្លែខ្នុរ និងត្រប់បែក | ចំណាយរយៈពេល**១ឆ្នាំ** (២០១៨-២០១៩) |
| ៣. ផ្លែក្រូចថ្លុង និងមៀន | ចំណាយរយៈពេល**២ឆ្នាំ** (២០១៨-២០២០) |

ផ្លែឈើ៤មុខផ្សេងទៀតរួមមាន សាវម៉ាវ ក្រូចឡឿង ទៀប និងក្រូចខ្វិច បាននិងកំពុងរៀបចំសេចក្តីព្រាងលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចេញ។ បន្ថែមពីនេះ ដោយមានតម្រូវការនាំចេញពីធុរជនក្នុងការនាំចេញផ្លែទុរេនទៅកាន់ប្រទេសវៀតណាម នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម ក៏បាននិងកំពុងរៀបចំឯកសារបច្ចេកទេសសម្រាប់ស្នើសុំបើកទីផ្សារនាំចេញទុរេនកម្ពុជាទៅកាន់ប្រទេសវៀតណាមផងដែរ។

❖ **ការចរចាបើកទីផ្សារជាមួយប្រទេសជប៉ុន**

អគ្គនាយកដ្ឋានកសិកម្ម និងនាយកដ្ឋានការពារដំណាំនៃប្រទេសជប៉ុន បានចាប់ផ្តើមដំណើរការចរចាស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចេញផ្លែស្វាយកម្ពុជាទៅកាន់ប្រទេសជប៉ុនចាប់តាំងពីឆ្នាំ២០១៨។ ក្នុងរយៈពេលប្រហែល៥ឆ្នាំមកនេះ ក្រុមការងារជំនាញកំពុងរៀបចំឯកសារវិទ្យាសាស្ត្រដើម្បីឆ្លើយតបតាមការតម្រូវរបស់ភាគីជប៉ុន។

❖ **នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម** បានរៀបចំគម្រោងស្នើសុំការជួយពី U.S. Department of Agriculture (USDA) and the U.S. Agency for International Development (USAID) សម្រាប់ជួយដល់ការចរចាបើកទីផ្សារស្វាយកម្ពុជាទៅកាន់សហរដ្ឋអាមេរិកផងដែរ។ បច្ចុប្បន្នឯកសារបច្ចេកទេសសម្រាប់ស្នើសុំបើកទីផ្សារនាំចេញផ្លែស្វាយទៅកាន់ U.S. បាននិងកំពុងរៀបចំ និងត្រៀមដាក់ជូន APHIS នៃ USDA ក្នុងពេលឆាប់ៗខាងមុខផងដែរ។

# ការនាំចេញកសិផលកម្ពុជាទៅកាន់ប្រទេសអេមីរ៉ាតអារ៉ាប់រួម (តោន)




ការនាំចេញកសិផលកម្ពុជាទៅកាន់ប្រទេសអេមីរ៉ាតអារ៉ាប់រួម
ចាប់ពីឆ្នាំ២០១៨ ដល់១០ខែឆ្នាំ២០២៤




ប្រភេទកសិផលកម្ពុជានាំចេញទៅកាន់
ប្រទេសអេមីរ៉ាតអារ៉ាប់រួម ក្នុងរយៈពេល១០ខែឆ្នាំ២០២៤

# ការនាំចេញកសិផលក្នុងរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២៣
# និងកសិផលសក្តានុពលនាំចេញទាំង១០



# ទិសដៅសំខាន់ៗនាំចូលកសិផលពីកម្ពុជាក្នុងឆ្នាំ២០២៣



# Total Export Destination of Milled Rice in 2023 (Tons)

## ASEAN Members




## China




## European Union




## Others




## Type of Milled Rice export in 2023Tons)







# Total Export of Milled Rice from 2019 to 2023 and Export Destination in 2023 (Tons)




**Total Export and Export Destination of Fresh Banana from 2019 to 2023 (Tons)**




Total Export of Cashew nut from 2019 to 2023 and Export Destination in 2023 (Tons)






**Total Export Destination of Cassava Products in 2023 compared to 2022 (Tons)**




Total Export Destination of Cassava Slices in 2023 (Tons)




Total Export Destination of Fresh Cassava in 2023 (Tons)




Total Export Destination of Cassava Starch in 2023 compared to 2022 (Tons)




**Total Export Destination of Cassava Residue in 2023 compared to 2022(Tons)**




| | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|
| Total | 3,310,092.41 | 2,288,527.20 | 2,793,728.92 | 3,727,547.86 | 3,362,166.84 |
| Cassava Slices | 1,626,165.01 | 1,516,476.06 | 1,644,591.68 | 2,068,086.47 | 1,289,739.04 |
| Fresh Cassava | 1,608,450.00 | 723,590.00 | 1,104,220.00 | 1,550,400.00 | 1,961,375.00 |
| Cassava Starch | 56,874.49 | 34,935.14 | 35,862.74 | 66,396.00 | 36,256.80 |
| Cassava Residue | 18,602.91 | 13,526.00 | 9,054.50 | 42,665.39 | 74,796.00 |

# Total Export of Cassava Products from 2019 to 2023and Export Destination in 2023 compared to 2022(Tons)




Total Export and Export Destination of Fresh Longan from 2019 to 2023 (Tons)

# Total Ecport Destination of Mango Products from 2021 to 2023 (Tons)




# Total Export Destination of Fresh Mango in 2023 compared to 2022 (Tons)




# Total Export Destination of Dried Mango in 2023 (Tons)







| | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|
| Total | 61,810.92 | 107,680.41 | 265,229.82 | 185,376.97 | 199,979.16 |
| Fresh Mango | 58,162.16 | 97,627.60 | 242,483.76 | 162,429.53 | 161,924.70 |
| Dried Mango | 2,712.16 | 6,401.77 | 17,879.86 | 18,491.792 | 27,387.77 |
| Mango Preserved | 928.00 | 3,651.04 | 4,866.18 | 4,424.21 | 10,639.85 |
| Pickled Mango | 8.60 | 0.00 | 0.00 | 0.20 | 24.00 |
| Chocolate dried mango | 0.00 | 0.00 | 0.00 | 0.00 | 2.84 |
| Mango skin meal | 0.00 | 0.000 | 0.020 | 31.24 | - |

# Total Export of Fresh Mango and Mango Products from 2019 to 2023 and Export Destination (Tons)

## Export Destination of Pepper in 2023 compared to 2022 (Tons)







# Total Export of Pepper from 2019 to 2023 and Export Destination in 2023 (Tons)

# សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង

- លោកបណ្ឌិត **កែ មុន្នីវុធ** ប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ
  E-mail: monthivuthker@gmail.com
  Tel: (855) 12 325 558
- លោកស្រីបណ្ឌិត **អុង សុជាតិ** អនុប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ
  E-mail: ongsocheath@yahoo.com
  Tel: (855) 092 622 621
- លោក **លី សិរីវុឌ្ឍ** ប្រធានការិយាល័យភូតគាមអនាម័យ
  E-mail: lysereivuth@gmail.com
  Tel: (855) 12 533 647
- លោក **ហូ ជា** មន្ត្រីបច្ចេកទេសនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ
  E-mail: ho.chea@yahoo.com
  Tel: (855) 77 426 608
- លោក **លួន ពិសី** មន្ត្រីបច្ចេកទេសនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ
  E-mail: l.pisey2015rs@gmail.com
  Tel: (855) 96 227 4509

អាស័យដ្ឋាន: អាគារលេខ 54B/49F ផ្លូវលេខ 395-656 សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ



# សូមអរគុណ

